ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

[redacted]

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៧៨
ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២
សាលដីកា
លេខ ២៧៥ VIII
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន
២.ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍
៣.ឯកឧត្តម [redacted] ជាចៅក្រម
៤.ឯកឧត្តម [redacted] ជាចៅក្រម
៥.ឯកឧត្តម [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១២២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៣២ (ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលមាន៖

**ជនជាប់ចោទ៖**

១. ឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតជំរុំសាវដាង ប្រទេសថៃ ទីលំនៅមុនពេលឃុំ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ[redacted] មានកូន ០៥នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ (ក្រៅឃុំ)



CamScanner

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០០ ព្រទ.III "ច"/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ នៅពន្ធនាគារខេត្តបន្ទាយមានជ័យ។

ដីកាបង្គាប់ឱ្យដោះលែងលេខ ១២ អយក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

មេធាវីការពារសិទ្ធិ លោក [redacted] ម៉ូវ៉ា ។

ជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] ស្រីមុំ ភេទស្រី កើតថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នភូមិ[redacted] ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ (គេចខ្លួន)

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៦អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង (អ្នកប្តឹងសាទុក្ខ)**

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលគោករមៀត បានធ្វើការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនឈ្មោះ [redacted] ឡា ដកហូតបានថ្នាំញៀនម៉ាទឹកកកមួយថង់ទម្ងន់ ៤៦,៣០ ក្រាម និងថ្នាំញៀនគ្រាប់ចំនួនមួយគ្រាប់។ ឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថា បានទិញថ្នាំញៀនពីឈ្មោះ ធី ឈ្មោះ រី និងឈ្មោះ[redacted] ស្រីមុំ យកមកប្រើប្រាស់ និងលក់បន្ត។

- **បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ០១ "អ"/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានសេចក្តីសម្រេចដូចតទៅ៖

១. ផ្តន្ទាទោស

ក. ឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវអាវ ប្រទេសថៃ។ អាសយដ្ឋានមុនពេលចាប់ខ្លួនភូមិវល្លិ៍ប្រេង[redacted] ខេត្តបន្ទាយមានជ័យ។ មុខរបរ

កសិករ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ៥ នាក់។ កម្រិតវប្បធម៌ ថ្នាក់ទី៦។ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២០០ ព្រទ.III"ច"/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១។

ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ)ឆ្នាំ ដោយទោសនេះឱ្យអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ៤ (បួន)ឆ្នាំ ទោសនៅសល់ពីនេះឱ្យព្យួរការអនុវត្តធម្មតាតាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] ស្រីមុំ ភេទស្រី ថ្ងៃ ខែ ឆ្នាំកំណើតទី៩ ខែមិថុនា ឆ្នាំ១៩៧៨ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អាសយដ្ឋានបច្ចុប្បន្នភូមិបន្ទាយមានឫទ្ធិ [redacted] ខេត្តបន្ទាយមានជ័យ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted]។ (គេចខ្លួន)។

ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (បួន)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ស្រីមុំ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.រឹបអូស ម្សៅក្រាមពណ៌សថ្លាទម្ងន់ ៤៦,៣០ ក្រាម (ទម្ងន់ ៤,១៧ ក្រាម បានបញ្ជូនទៅធ្វើកោសលវិច័យ) មានបរិមាណសុទ្ធ ៣៤,៤៧ ក្រាម និងទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក Vfone ពណ៌ក្រហម។

"វត្ថុចាប់យកទាំងនេះ ត្រូវបានរក្សាទុកដោយមន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តបន្ទាយ-មានជ័យ តាមកំណត់ហេតុទទួលវត្ថុតាងលេខ ១១៩ អ.យ.គ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១"។

៤. សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឡា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស្រីមុំ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។



CamScanner

- **បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ០៨ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ឡា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ “ក”/០២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

- **បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៤៣២ (ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ឡា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ០១ “ក”/០២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ចោលជាអសារបង់។

៣.ឱ្យឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ ជនជាតិខ្មែរ ទីកន្លែងកំណើតជំរុំសាវដាង ប្រទេសថៃ អាសយដ្ឋានមុនពេលចាប់ខ្លួនភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មុខរបរ កសិករ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៥ នាក់ កម្រិតវប្បធម៌ថ្នាក់ទី៦ ទោសពីមុនគ្មាន រួចផុតពីបទចោទប្រកាន់ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១។

៤.បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] ឡា នេះចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ។

សាលដីកានេះប្រកាសជាសាធារណៈ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

- **បានឃើញ** បណ្តឹងសាទុក្ខលេខ ១២២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៣២ (ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍បាត់ដំបងមានមូលហេតុត្រឹមត្រូវតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយជនជាប់ចោទឈ្មោះ [redacted] ឡា បានទទួលស្គាល់នៅនគរបាលយុត្តិធម៌ ថាខ្លួនពិតជាបានរក្សាទុកគ្រឿងញៀនពិតប្រាកដមែន។ ហេតុដូច្នេះ ប្តឹងសុំក្រុមប្រឹក្សាសម្រេចបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤៣២



CamScanner

(ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ចោល និងបញ្ជូលសំណុំរឿងទៅសាលាឧទ្ធរណ៍បាត់ដំបងវិញ ដើម្បីជំនុំជម្រះជាថ្មី ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឡា បានធ្វើសេចក្តីសន្និដ្ឋានថា ពេលសមត្ថកិច្ចដកហូតសារធាតុញៀននោះគឺមិនមានឈ្មោះ [redacted] ឡា ទេ ប៉ុន្តែនៅពេលចាប់ខ្លួន និងឆែកឆេរផ្ទះរបស់ [redacted] ឡា ទើបឃើញមានថ្នាំញៀន។ ឈ្មោះ [redacted] ឡា បានឆ្លើយនៅមុខនគរបាលដោយរងនូវការបង្ខិតបង្ខំ ចំណែកនៅមុខព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរគាត់បានបដិសេធចម្លើយដែលបានឆ្លើយនៅចំពោះមុខនគរបាល។ ក្នុងពេលសវនាការសាលាដំបូង និងសាលាឧទ្ធរណ៍ឈ្មោះ [redacted] ឡា នៅតែអះអាងថាគាត់បានប្រើប្រាស់ តែមិនបានជួញដូរគ្រឿងញៀនទេ។ ពេលដែលរឹបអូសគ្រឿងញៀន មិនមានវត្តមានរបស់ [redacted] ឡា ទេ តើសារធាតុញៀនជារបស់ [redacted] ឡា មែនឬទេ? ឈ្មោះ មុំ ជាអ្នកលក់សារធាតុញៀន ដែលជាសាក្សីសំខាន់ពាក់ព័ន្ធក្នុងសំណុំរឿងនេះបានគេចខ្លួន។ នៅមានមន្ទិលជាច្រើនដែលសាលាឧទ្ធរណ៍យល់ថាសំអាងហេតុរបស់សាលាដំបូងមិនគ្រប់គ្រាន់ សាលាឧទ្ធរណ៍ទំនងជាផ្តល់ទម្ងន់ទៅលើចម្លើយមុខព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរជាងចម្លើយនៅមុខនគរបាលយុត្តិធម៌។ ដូចនេះ ចម្លើយនៅមុខនគរបាលមិនអាចយកមកកំណត់ពិរុទ្ធភាពទេ សាលដីកាសម្រេចឱ្យរួចផុតពីបទចោទមានសំអាងហេតុគ្រប់គ្រាន់។ ក្នុងករណីដែល [redacted] ឡា មិនបានប្រព្រឹត្តអំពើជួញដូរតាមអង្គហេតុថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ ទេ គាត់សមល្មមនឹងត្រូវបានដោះលែង ។

សំណូមពរ សូមអង្គជំនុំជម្រះសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍បាត់ដំបង និងតម្កល់សាលដីកាសាលាឧទ្ធរណ៍បាត់ដំបងទុកជាបានការ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១២២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



CamScanner

២-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ០១ ក/០២ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចផ្តន្ទាទោសដល់ជនជាប់ចោទ២នាក់ គឺ[redacted] ឡា និង [redacted] ស្រីមុំ ហើយសាលក្រមនេះ[redacted] ឡា បានប្តឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បាត់ដំបងបានសម្រេចបដិសេធសាលក្រមខាងលើចោល និងសម្រេចឱ្យជនជាប់ចោទ[redacted] ឡា រួចខ្លួនពីបទចោទ ដែលការសម្រេចនេះទាក់ទងដល់ជនជាប់ចោទឈ្មោះ [redacted] ស្រីមុំ ដែលមិនបានប្តឹងឧទ្ធរណ៍ ពោលគឺសាលាឧទ្ធរណ៍បាត់ដំបងពិនិត្យ និងសម្រេចលើសពីឧបាស្រ័យ។

៣-យល់ឃើញថា ដីកាបញ្ជូនរឿងឱ្យស៊ើបសួរក្តី ដីកាដំណោះស្រាយក្តី សុទ្ធតែបានប្តឹងពីអង្គហេតុនៃបទល្មើសនាថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ប៉ុន្តែការយល់ឃើញរបស់សាលាដំបូងបានលើកយកចម្លើយ ជនជាប់ចោទ[redacted] ឡា នៅដំណាក់កាលនគរបាលថា ខ្លួនបានធ្វើសកម្មភាពលក់ថ្នាំញៀនរយៈពេលកន្លះឆ្នាំ មកហើយ ដែលជាអង្គហេតុផ្សេងពីការបញ្ជូនរឿងឱ្យស៊ើបសួរ ដែលការណ៍លេចហេតុបែបនេះ ព្រះរាជអាជ្ញាគប្បីបើកការស៊ើបសួរបន្ថែមតាមនីតិវិធី ប៉ុន្តែកិច្ចបែបនេះមិនត្រូវបានធ្វើទេ។

៤-យល់ឃើញថា សាលាឧទ្ធរណ៍បាត់ដំបងបានធ្វើសម្អាងហេតុអំពីភស្តុតាង ដែលអាចសអោយឃើញថា អំពើល្មើសនេះមិនពាក់ព័ន្ធផ្ទាល់ដល់ជនជាប់ចោទ ហើយមេធាវីការពារក្តីអោយជនជាប់ចោទក៏បាន ឯកភាពតាមការយល់ឃើញរបស់សាលាឧទ្ធរណ៍ និងបានលើកពីវិមតិសង្ស័យ ឬភស្តុតាងមានលក្ខណៈមិនពេញលេញ គឺត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទនោះ ជាគោលការណ៍ គឺមានលក្ខណៈត្រឹមត្រូវពិតមែន ប៉ុន្តែចំពោះរឿងក្តីនេះ ដោយសារមន្ត្រីនគរបាលយុត្តិធម៌ក្តី និងដំណាក់កាលបន្តបន្ទាប់ ជាពិសេសការស៊ើបសួរ ភាពពាក់ព័ន្ធហាក់នៅមានចន្លោះប្រហោងខ្លះ ដូចជាការទៅយកខោអាវពីផ្ទះជនជាប់ចោទ តើខោអាវនោះជាខោអាវរបស់អ្នកណា? អ្នករស់នៅក្នុងផ្ទះនោះមានអ្នកណាខ្លះ? អ្នកទូរស័ព្ទសួរសាក្សីប្រមូលខោអាវទៅធ្វើការបោកគក់ សួររកថង់ខ្មៅ មានមែនឬទេ? និងហេតុផលផ្សេងទៀតដែលគប្បីយកចិត្តទុកដាក់មុននឹងធ្វើការដាក់ទោស។ ក្នុងស្ថានភាពបច្ចុប្បន្ន ការប្រព្រឹត្តល្មើសជួញដូរគ្រឿងញៀនខុសច្បាប់នេះ ហាក់មានសន្ទុះ និងគ្រប់ទីកន្លែង ដែលបង្កអោយសង្គមមានបរាជ័យគ្រប់យ៉ាង ដូច្នេះ ភាពចាំបាច់នៃការអង្កេតបន្ថែម គួរតែត្រូវបំពេញ។

៥-យល់ឃើញថា នាដំណាក់កាលអង្កេតក្តី នាដំណាក់កាលជំនុំជម្រះក្តី តំណាងអយ្យការហាក់មិនបានលើកហេតុផល ភស្តុតាង ដើម្បីទាមទារអោយមានការបំពេញកិច្ចបន្ថែមដោយសកម្មទេ ពិសេសទោះក្នុងលិខិតសន្និដ្ឋានជាលាយលក្ខណ៍អក្សរក៏ពឹងផ្អែកជូនតុលាការសម្រេចតាមច្បាប់ ដោយឡែកចំពោះបណ្តឹងសាទុក្ខនេះ ក៏មិនបានពិនិត្យដល់ការសម្រេចបដិសេធចោលសាលក្រមរបស់សាលាដំបូង ហើយតំណាងមហាអយ្យការក៏មិនបានលើកដូចបានយល់ឃើញក្នុងចំណុចទី២ ខាងលើក៏ដោយ ប៉ុន្តែនេះជាកំហុសអង្គច្បាប់ ដែលគប្បីបង្វិលទៅតុលាការអង្គហេតុសម្រេចអោយបានត្រឹមត្រូវឡើងវិញ។



CamScanner

៦-យល់ឃើញថា បណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងមានមូលហេតុស្របនឹងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៣២ (ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង សម្រេចពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ឡើយ ។ [redacted]

## ហេតុដូច្នេះ

## សម្រេច

១. ទទួលបណ្តឹងសាទុក្ខលេខ ១២២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

២. បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៤៣២ (ខ) ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

៣. បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៨ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍បាត់ដំបងដើម្បីជំនុំជម្រះសាជាថ្មី ។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃពុធ ១៣រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃពុធ ១៣រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]